3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧២៩០.០ សហវ.ហក

ក្រសួងសុខាភិបាល
30 - 6 - 2009
2313

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ ២០០៩

គោរពជូន

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**កម្មវត្ថុ:** សំណើមានវិធានការតឹងតៀត សន្សំសំចៃ ដើម្បីកាត់បន្ថយចំណាយដំណើរការរដ្ឋបាល។

**យោង:**
- ព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- សារាចរលេខ ០០៥ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការណែនាំលើការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២
- ការណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៩

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ពិសេសបន្ទាប់ពីបានទទួលការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជាកំពុងរងផលប៉ះពាល់ពីវិបត្តិនៃគលិយុគហិរញ្ញវត្ថុអន្តរជាតិ និងឱនភាពសេដ្ឋកិច្ចសាកលលោក ដើម្បីរក្សាបាននូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ច រក្សាបាននូវអធិបតេយ្យភាព ប្រសិទ្ធភាពចំណាយថវិកា និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមស្នើឯកឧត្តម ក្នុងនាមជាអាណាប័កដើមខ្សែ និងជាអាណាប័កតាមការប្រទានសិទ្ធ មេត្តាណែនាំ<u>*ដាក់វិធានការសន្សំសំចៃ និងគ្រប់គ្រងចំណាយឱ្យមានប្រសិទ្ធភាពខ្ពស់បំផុតក្នុងកិច្ចដំណើរការរដ្ឋបាល ដូចជា ៖*</u>

- <u>*ចំណាយលើការប្រើប្រាស់ប្រេងឥន្ធនៈ:*</u> ៖ ត្រូវគ្រោងគិតឱ្យបានត្រឹមត្រូវតាមចំនួនរថយន្ត និងមធ្យោបាយយានយន្តផ្សេងទៀត ដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌពិតប្រាកដ និងកំពុងដំណើរការជាក់ស្តែង ។ រថយន្តផ្ទាល់ខ្លួនអនុញ្ញាតឱ្យគ្រោងថ្លៃចំពោះតែរថយន្តរបស់មន្ត្រីថ្នាក់ដឹកនាំ ចាប់ពីថ្នាក់អគ្គនាយក ឬអគ្គលេខាធិការឡើង <u>ដែលមិនមាន</u>



ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_admin@yahoo.com

មធ្យោបាយរបស់រដ្ឋប្រើប្រាស់ ។ រីឯមន្ត្រីជាប់កិច្ចសន្យា ឬទីប្រឹក្សាដែលមានឋានៈស្មើ មិនអនុញ្ញាតជូនឡើយ ។ ចំពោះគម្រោងចំណាយទិញប្រេងឥន្ធនៈ ត្រូវបន្តអនុវត្តតាមបរិមាណដែលបានកំណត់បណ្តោះអាសន្នកន្លងមក ដោយផ្អែកលើថ្លៃប្រេងលើទីផ្សារបច្ចុប្បន្ន ។

- *អគ្គិសនី ទឹក និងទូរស័ព្ទ* ៖ កាត់បន្ថយ និងសន្សំសំចៃឱ្យស្ថិតក្នុងកម្រិតមួយសមស្រប និងចាំបាច់ ដោយត្រូវកាត់បន្ថយជាអតិបរមានូវការប្រើប្រាស់ទាំងឡាយណាដែលមិនបម្រើផលប្រយោជន៍របស់ក្រសួង ស្ថាប័ន ។

- *សម្ភារៈការិយាល័យ សម្ភារៈបរិក្ខារប្រើប្រាស់ និងគ្រឿងសង្ហារឹម* - ត្រូវសុំចំណាយតែក្នុងករណីចាំបាច់ ដូចជាមានការប្រែប្រួលមន្ត្រីរាជការ ឬត្រូវបំពាក់សម្ភារៈឱ្យអង្គភាពទើបបង្កើតថ្មី ។ ចំពោះគ្រឿងសង្ហារឹមរបស់ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ក៏មិនត្រូវឱ្យមានលក្ខណៈទំនើបហួសហេតុពេកទេ ។

- *ការជួសជុលអគារ និងសាងសង់ថ្មី* - ត្រូវផ្អាកជាបណ្តោះអាសន្ននូវការសាងសង់ថ្មី និងជួសជុលអគារគ្រប់ប្រភេទ លើកលែងតែក្នុងករណីដែលអគារនោះមានភាពទ្រុឌទ្រោមខ្លាំងដែលត្រូវការជួសជុលជាបន្ទាន់ ។

- *ការទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច* - មិនត្រូវមានភាពហ៊ឺហា គគ្រឹកគគ្រេងហួសហេតុ ហើយចំណាយត្រូវឱ្យស្របតាមរបបកំណត់ ដូចជារបបបេសកកម្ម និងស្នាក់នៅជាដើម ។

- *បេសកកម្មក្នុង និងក្រៅប្រទេស* - គួរគប្បីធ្វើអាទិភាពភាវូបនីយកម្មបេសកកម្ម ដោយត្រូវផ្អាក ឬលុបចោលនូវបេសកកម្មណាដែលមិនចាំបាច់ ឬដែលអាចជំនួសបានដោយស្ថានតំណាងរបស់ប្រទេសកម្ពុជានៅប្រទេសដែលត្រូវបំពេញបេសកកម្មនោះ ។ម្យ៉ាងទៀត គួរខិតខំកាត់បន្ថយឱ្យនៅជាអប្បបរមានូវចំនួនសមាជិកប្រតិភូដែលត្រូវចូលរួម ។ របបបេសកកម្មគប្បីជូនចំពោះតែមន្ត្រីណាដែលមានឋានន្តរស័ក្តិពិតប្រាកដនៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នរដ្ឋប៉ុណ្ណោះ ដោយមិនរួមបញ្ចូលនូវបុគ្គលិកជាប់កិច្ចសន្យា ឬទីប្រឹក្សាដែលមានឋានៈស្មើឡើយ ។

- *ការទិញរថយន្ត* - ត្រូវផ្អាកការចំណាយនេះ លើកលែងតែមានការសម្រេចដោយឡែកពីរាជរដ្ឋាភិបាល ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹម និងជឿជាក់យ៉ាងមុតមាំលើស្មារតីទទួលខុសត្រូវរបស់ ឯកឧត្តម ក្នុងនាមជាអាណាប័កដើមខ្សែ ឬជាអាណាប័កតាមការប្រទានសិទ្ធ ក្នុងការដាក់ចេញនូវវិធានការអនុវត្តជាក់ស្តែងឱ្យបានជោគជ័យ តាមគោលការណ៍នយោបាយសន្សំសំចៃដែល សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព ។

សូមឯកឧត្តម មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ៕

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន៖
- ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា«ដើម្បីជ្រាបជារបាយការណ៍»
- អង្គភាពពាក់ព័ន្ធចំណុះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ឯកសារ-កាលប្បវត្តិ

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម
សំរាប់ចែកជូនអង្គភាពក្រោមឱវាទ ។
ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៩
អគ្គនាយករងរដ្ឋបាល ហិរញ្ញវត្ថុ

សាស្ត្រាចារ្យ ភឿត_សៀង